00426515

C26/9/2

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៣៦) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 01 / 2010
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ / Public (Redacted Version)

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ
លោក Tarik ABDULHAK

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING, QC
ចៅក្រម ន៉ី ធុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING

**ជនត្រូវចោទ និង ក្រុមមេធាវី:**
**ខៀវ សំផន**
លោក សរ សូវ៉ាន
លោក Jacques VERGÈS

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANNONE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី
លោក ឡោ ជុនធី
កញ្ញា SILKE Studzinsky
លោក គង់ ពិសី

លោក ហុង គឹមសួន
លោក យុង ផានិត
លោក Pierre-Olivier SUR
លោកស្រី ស៊ីន សុវ៉ន
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក Olivier BAHOUGNE
លោក David BLACKMAN

## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ (“បណ្តឹងឧទ្ធរណ៍”)[1] ដើម្បីស្វែងរកការកែប្រែដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) បន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ខៀវ សំផន (“ជនត្រូវចោទ” ឬ “ដើមបណ្តឹងឧទ្ធរណ៍”) សម្រាប់រយៈពេលបន្តទៀតមិនលើសពីមួយឆ្នាំ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ (“ដីកាសម្រេចបន្តឃុំខ្លួនលើកទីពីរ”)[2] ។

២. មេធាវីការពារក្តីតវ៉ាថា ជនត្រូវចោទគួរតែត្រូវបានដោះលែងដោយសារ (១)ការបកស្រាយរបស់ ស.ច.ស ចំពោះវិធាន៦៣.៧ នៃវិធានផ្ទៃក្នុង មានការភ័ន្តច្រលំ ពីព្រោះដីកាសម្រេចបន្តឃុំខ្លួនលើកទីពីរមិនបាន”ឈរលើសំអាងហេតុដែលមានសុពលភាពណាមួយទេ ហើយមាន “ការពេញចិត្តក្នុងការលើកឡើងពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨”[3], (២) លក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ៦៣.៣.ក មិនបានបំពេញឡើយ ដោយសារគ្មាន “មូលហេតុដែលត្រូវបានរកឃើញ” និងជឿជាក់យ៉ាងច្បាស់ថា ដើមបណ្តឹងឧទ្ធរណ៍អាចបានប្រព្រឹត្តបទឧក្រិដ្ឋនានា ដូចដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[4], (៣) ការដោះលែងដើមបណ្តឹងឧទ្ធរណ៍ឲ្យមានសេរីភាព គ្មានហានិភ័យដល់កិច្ចដំណើរការនីតិវិធីដែលកំពុងតែដំណើរការទេ ដូចដែលមានការរំពឹងទុកនៅក្នុងវិធាន ៦៣.៣.ខ.៣.១, ៦៣.៣.ខ.៣.២ និង ៦៣.៣.ខ.៣.៣[5], (៤) ដីកាសម្រេចបន្តឃុំខ្លួនលើកទីពីរ មិនមានចែងអំពីភស្តុតាងណាមួយគាំទ្រដល់ការសន្និដ្ឋានជាចុងក្រោយដែលថា សុវត្ថិភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ នឹងមានគ្រោះថ្នាក់ឡើយ បើសិនជាគាត់ត្រូវបានគេដោះលែងឲ្យមានសេរីភាព[6], (៥) គេមិនអាចនិយាយបានថា ការដោះ

[1] *ករណីរបស់ ខៀវ សំផន*, សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារថិរវេលាឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨, ឯកសារលេខ: C26/9/1, ERN 00420912-21 (ភាសាអង់គ្លេស), ដែលបានជូនដំណឹងដល់គូភាគីនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨ [ចាប់ពីនេះតទៅហៅថា “បណ្តឹងឧទ្ធរណ៍”] ។

[2] *ករណីរបស់ ខៀវ សំផន*, ដីកាសម្រេចអំពីការបន្តថិរវេលានៃឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារលេខ: C26/8, ERN 00404681-00404693 (ភាសាអង់គ្លេស), [ចាប់ពីនេះតទៅហៅថា “ដីកាសម្រេចបន្តឃុំខ្លួនលើកទីពីរ”] ។

[3] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី៧, ៨ និងទី៩ ។

[4] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១០, ១១, ១២ និង ១៣ ។

[5] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១៤, ១៥ ។

[6] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១៦, ១៧, ១៨, និង ១៩ ។

លែងជើមបណ្តឹងឧទ្ធរណ៍ឱ្យមានសេរីភាពនឹងបង្កឱ្យមានការរំខានជាក់ស្តែង និងចាំបាច់ណាមួយ ចំពោះសណ្តាប់ធ្នាប់សាធារណៈទេ[7] និង (៦) ការដោះលែងជើមបណ្តឹងឧទ្ធរណ៍ឱ្យមានសេរីភាព គឺជាវិធានការសមហេតុផលតែមួយគត់ ដោយសារកង្វះខាតនៃការយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់ នៅក្នុងផ្នែកនៃកិច្ចស៊ើបសួររបស់ស.ច.ស[8] ព្រមទាំងមានការលំអៀងជាប្រព័ន្ធនៅក្នុងផ្នែក ស.ច.ស[9] ។

៣. សហព្រះរាជអាជ្ញាសូមស្នើឱ្យអ.ប.ជ ច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារមូលហេតុផ្សេងៗ ដូចតទៅនេះ នៅក្នុងចំណោមមូលហេតុដទៃទៀត ៖

(ក) ដីកាសម្រេចបន្តឃុំខ្លួនលើកទីពីរ ពិតជាបានផ្តល់មូលហេតុគ្រប់គ្រាន់ និងសមល្មម ដែលផ្ទុយទៅនឹងការអះអាងរបស់ជើមបណ្តឹងឧទ្ធរណ៍ ទាក់ទងទៅនឹងការបកស្រាយខុស នូវវិធាន៦៣(៧)របស់ ស.ច.ស។ សចស បានកំណត់អំពីទឡ្ហីករណ៍ច្បាប់ និងអង្គហេតុដែល ស.ច.ស បានលើកយកជាសំអាងសម្រាប់សេចក្តីសម្រេចរបស់ខ្លួន។ ក្នុងកាលៈទេសៈណាក៏ដោយ ស.ច.ស មិនជាប់កាតព្វកិច្ច ត្រូវតែបង្ហាញឱ្យឃើញនូវទស្សនៈណាមួយលើគ្រប់កត្តាទាំងអស់ ដែលបានលើកឡើងដោយជើមបណ្តឹងឧទ្ធរណ៍ ។

(ខ) ជើមបណ្តឹងឧទ្ធរណ៍បានខកខានក្នុងការបង្ហាញឱ្យឃើញអំពី ការកែប្រែនៃកាលៈទេសៈជាក់ស្តែងណាមួយ តាំងពីជើមបណ្តឹងឧទ្ធរណ៍ត្រូវបានឃុំខ្លួនដោយសចសកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧("ដីកាឃុំខ្លួន")[10]ហើយមានសេចក្តីសម្រេចរបស់ អ.ប.ជ លើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨ មក ("សាលដីកា

---

[7] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី២៣ និង ២៥ ។

[8] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី២៧ ។

[9] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី៣៣ ។

[10] *ករណីរបស់ ខៀវ សំផន*, ដីកាឃុំខ្លួនបណ្តោះអាសន្នថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ C26, ERN 00152991-96 (FRE), 00156700-05 (ENG) and 00152973-78 (KHM) (hereinafter "Detention Order").

របស់អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន")[11] ។ នៅក្នុងសេចក្តីសម្រេចនោះ អ.ប.ជ បានវាយតម្លៃលើភស្តុតាងទាំងអស់ នៅក្នុងសំណុំរឿងរហូតមកដល់ថ្ងៃសវនាការ និងបានសម្រេចថា លក្ខខណ្ឌតម្រូវនានាដូចមានចែងនៅក្នុងវិធាន ៦៣.៣.ក និង វិធាន ៦៣.៣ .ខ.៤ និង ៦៣.៣.ខ.៥ ត្រូវបានបំពេញ ហើយការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទនិងរក្សាសណ្តាប់ធ្នាប់សាធារណៈ[12]។ នៅក្នុងដំណាក់កាល នៃកិច្ចស៊ើបសួរចុងក្រោយនេះ សំណុំរឿងមានផ្ទុកនូវភស្តុតាងគ្រប់គ្រាន់សមល្មម ដែលអាចបំពេញតាមចិត្តរបស់អ្នកសង្កេតការណ៍ឯករាជ្យបាន ដែលថា ដើមបណ្តឹងឧទ្ធរណ៍ អាចបានប្រព្រឹត្តបទឧក្រិដ្ឋដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ លើសពីនោះទៀតលក្ខខណ្ឌពីរក្នុងចំណោមលក្ខខណ្ឌទាំងប្រាំដែលខុសគ្នា ដែលចាំបាច់សម្រាប់ការឃុំខ្លួនដូចមានចែងក្នុងវិធាន៦៣(៣)(ខ)(iv)និង(v) សម្រាប់បន្តយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្នដើមបណ្តឹងឧទ្ធរណ៍។

(គ) ការតវ៉ារបស់មេធាវីការពារក្តីដែលថា ស.ច.ស បានរំលោភជាប្រព័ន្ធទៅលើសិទ្ធិនៃការសន្មតជាមុនថាគ្មានទោសរបស់ដើមបណ្តឹងឧទ្ធរណ៍ គឺជាការមិនត្រឹមត្រូវ ដោយសារថា រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន មិនមែនមិនមានហេតុផលនោះទេ ហើយក៏គ្មានកង្វះខាតក្នុងផ្នែកនៃការយកចិត្តទុកដាក់ហ្មត់ចត់របស់ ស.ច.ស នៅក្នុងកិច្ចស៊ើបសួរដែរ។ ការពិត លទ្ធផលចេញពីការវាយតម្លៃលើភស្តុតាងដែលបានបន្ថែមនៅក្រោយថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងភស្តុតាងនានាដែលបានដាក់រួចហើយនៅក្នុងសំណុំរឿង ក្រោយពីការចេញដីកាសម្រេចបន្តឃុំខ្លួនលើកទីពីរ ស.ច.ស បានជូនដំណឹងដល់ដើមបណ្តឹងឧទ្ធរណ៍ថា [redacted] ។

---

[11] *ករណីរបស់ ខៀវ សំផន,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩, ឯកសារលេខ: C26/5/36, ERN 00346164-204 (ភាសាអង់គ្លេស), [ចាប់ពីនេះតទៅហៅថា "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ.ប.ជ"] ។

[12] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះលើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ១៩០

[13] *ករណីរបស់ ខៀវ សំផន,* កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ: D285, ERN 00417984-89 (ភាសាអង់គ្លេស) ។

00426520



នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរនេះ សំណុំរឿងមានផ្ទុកនូវភស្តុតាងគ្រប់គ្រាន់សមល្មមដែលអាចបំពេញតាមចិត្តរបស់អ្នកសង្កេតការណ៍ឯករាជ្យបាន ដែលថាដើមបណ្ដឹងឧទ្ធរណ៍អាចបានប្រព្រឹត្តបទឧក្រិដ្ឋដែលគាត់កំពុងទទួលការចោទប្រកាន់ ។

(ឃ) ការតវ៉ារបស់មេធាវីការពារក្ដីដែលថា "ភាពលំអៀងជាប្រព័ន្ធយ៉ាងច្បាស់ក្រឡែត" នោះគឺជាការប្រឈមមុខទៅនឹងប្រតិបត្តិការរបស់ ស.ច.ស ដែលបញ្ហាទាំងអស់នោះ ត្រូវផ្ដាក់ទៅលើអង្គបុរេជំនុំជម្រះ ។ លើសពីនេះ កិច្ចដំណើរការនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ទាំងអស់មិនមែនជាវេទិកាសមស្រប ដើម្បីលើកឡើងពីបណ្ដឹងតវ៉ា ដែលទាកទិនទៅនឹងភាពអនាគតិរបស់ សចស ។ ការអះអាងទាំងនេះត្រូវបានបដិសេធចោលរួចហើយនៅក្នុងកិច្ចដំណើរការនីតិវិធីដាច់ដោយឡែក។ ជាងនេះទៀត ដូចគ្នានេះដែរ វាគ្មានផលប៉ះពាល់លើបញ្ហានៃការឃុំខ្លួនបណ្ដោះអាសន្ន លើដើមបណ្ដឹងឧទ្ធរណ៍ឡើយ។

(ង) អ.ប.ជ បានដោះស្រាយរួចរាល់ហើយលើបញ្ហាទាក់ទិននឹងសិទ្ធិ និងកាតព្វកិច្ចនៃការបកប្រែរបស់គូភាគី ។ អាស្រ័យហេតុនេះ ការតវ៉ារបស់ដើមបណ្ដឹងឧទ្ធរណ៍ដែលថា ខ្លួនគ្មានលទ្ធភាពដោយប្រសិទ្ធិភាព ដើម្បីរកភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង គឺជាការតវ៉ាច្រំដែលៗ និងត្រូវបានរារាំងតាមរយៈ*អាជ្ញាអស់ជំនុំ* ។

## ២. ច្បាប់

### *លក្ខខណ្ឌចាំបាច់សម្រាប់ការឃុំខ្លួន*

៤. តាមវិធាន ៦៣.៣ សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នបាន ប្រសិនបើ៖

(ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ចុងចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋនានា ដូចដែលបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ; និង

(ខ) សហចៅក្រមស៊ើបអង្កេតពិចារណាថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បី៖

(១) រារាំងកុំឱ្យជនត្រូវចោទនោះ គាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិត ។

(២) ថែរក្សាភស្តុតាង ឬ ការពារមិនឱ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទ នៅក្នុងដំណើរការនីតិវិធី ។

(៤) ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ ។

៥. ទឡ្ហីករណ៍ទាំងប្រាំដែលមានចែងនៅក្នុងវិធាន ៦៣.៣.ខ នៃវិធានផ្ទៃក្នុង គឺដាច់ៗគ្នា[14] ។ ពុំមានលក្ខខណ្ឌតម្រូវណាមួយដែលថា សហចៅក្រមស៊ើបអង្កេតត្រូវតែរកឱ្យឃើញថា គ្រប់ទឡ្ហីករណ៍ទាំងអស់ត្រូវតែបានបំពេញ មុននឹងពិចារណាអំពីការឃុំខ្លួនបណ្ដោះអាសន្នដែលជាវិធានការចាំបាច់ ឬថា ការបន្តថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានអនុញ្ញាតនោះទេ។ ផ្ទុយមកវិញ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាថា មានទឡ្ហីករណ៍មួយ ក្នុងចំណោមទឡ្ហីករណ៍ទាំងប្រាំ នោះការសាកល្បងសម្រាប់ការឃុំខ្លួន គឺត្រូវបានបំពេញហើយ ។ អភិក្រមនេះត្រូវបានយកទៅអនុវត្តនៅតាមបណ្ដាសាលាក្ដីព្រហ្មទណ្ឌដទៃទៀតដែរ ដែលធ្វើការដោះស្រាយលើបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរស្រដៀងគ្នា[15] ។

## ***ភារកិច្ចត្រូវផ្ដល់សំអាងនៅក្នុងដីកាសម្រេចឃុំខ្លួន***

[14] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្ដោះអាសន្ន, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០៣) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, ឯកសារលេខ C22/I/74, ERN 00232976-004, (ភាសាអង់គ្លេស), កថាខណ្ឌទី១២១, [*ចាប់ពីនេះតទៅហៅថា* "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី"] ។

[15] *រដ្ឋអាជ្ញា ទល់នឹង Sainovic និង Odjanic,* សាលដីកាបដិសេធការអនុញ្ញាតប្ដឹងឧទ្ធរណ៍របស់ Odjanic, សំណុំរឿងលេខ: IT-99-37-AR65.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣, ទំព័រ ៣, ERN 00154039-42 និងដែលបានអនុម័តយកតាមដោយ អ.ប.ជ នៃ អ.វ.ត.ក ក្នុង*ករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច,* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០១), ឯកសារលេខ: C5/45, ERN 00154284-302 (ភាសាអង់គ្លេស), កថាខណ្ឌទី៥៩ [*ចាប់ពីនេះតទៅហៅថា* "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន ឌុច"] ។

៦. វិធាន៦៣.៧ នៃវិធានផ្ទៃក្នុងតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត "ត្រូវមានសំអាងហេតុ" ចំពោះការពន្យារពេលនៃការបន្តឃុំខ្លួនបណ្តោះអាសន្ន ។ សំអាងហេតុទាំងនេះត្រូវតែផ្តល់ បន្ទាប់ពីមានការពិចារណាលើសំណុំរឿង និងការជំទាស់ផ្សេងៗពីជនជាប់ឃុំ[16] ។ ដោយសំអាងទៅលើយុត្តិសាស្ត្រអន្តរជាតិដែលត្រូវបានគេបង្កើតឡើង អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានរកឃើញថា រាល់សេចក្តីសម្រេចទាំងអស់នៃស្ថាប័ននានារបស់តុលាការ ដែលរួមទាំង ស.ច.ស ផង ត្រូវតែផ្តល់មូលហេតុសំអាង ដើម្បីបំពេញឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិ[17] ។

៧. អ.ប.ជ បានកំណត់ថា កាតព្វកិច្ចដែលត្រូវបញ្ជាក់ពីមូលហេតុផ្សេងៗ គឺគ្រាន់តែតម្រូវឱ្យ ស.ច.ស លើកពីហេតុផលខាងអង្គច្បាប់ និងពីអង្គហេតុដែលត្រូវយកចិត្តទុកដាក់ពិចារណាមុននឹងឈានទៅដល់ការធ្វើសេចក្តីសម្រេច ។ អ.ប.ជ អាចបំពេញកាតព្វកិច្ចនេះ បាន"ដោយជាទូទៅគឺយោងទៅលើសំណុំរឿង និងទៅលើកាលៈទេសៈផ្សេងៗទៀត" ដោយមិនបានតម្រូវឱ្យ ស.ច.ស បញ្ជាក់ពីការយល់ឃើញលើគ្រប់កត្តាទាំងអស់នោះទេ[18] ។

## *លក្ខណៈ និងវិសាលភាពនៃការពិនិត្យឡើងវិញរបស់ អ.ប.ជ*

៨. បញ្ហាសំខាន់ក្នុងការកំណត់ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននោះ គឺថាតើលក្ខខណ្ឌដែលចែងនៅក្នុងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុង នៅ

---

[16] អនុលោមតាមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុងដំណើរការនីតិវិធីនៃការពន្យាពេលនៃការបន្តឃុំខ្លួនបណ្តោះអាសន្នធ្វើឡើងតែរវាង ស.ច.ស និងជនយត្រូវចោទតែប៉ុណ្ណោះគត់ ដោយនៅមុនការពន្យាពេលនៃការបន្តឃុំខ្លួនបណ្តោះអាសន្នន ស.ច.ស សវនាការស្តាប់តែការជំទាស់របស់ជនត្រូវចោទប៉ុណ្ណោះ។ គ្មានភាគីណាផ្សេងទៀតត្រូវបានបើកធ្វើសវនាការដើម្បីស្តាប់ ឬត្រូវបានចូលរួមនៅក្នុងដំណើរការនេះទេ។ អាស្រ័យហេតុនេះ ដំណើរការនីតិវិធីនៃការពន្យាពេលនៃការបន្តឃុំខ្លួនតាមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុងមានភាពខុសគ្នាយ៉ាងជាក់ច្បាស់ពីដំណើរការនីតិវិធីនៃការឃុំខ្លួនបឋមអនុលោមតាមវិធាន៦៣.៣ ដែលរួមមានសវនាការតទល់គ្នាមួយនៅចំពោះមុខ ស.ច.ស ផង។

[17] *ករណីរឿងរបស់ នួន ជា* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ដែលប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី២៨ សីហា ២០០៨, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ស.ច.ស (អ.ប.ជ ០៦), ឯកសារលេខ D 55/I/8, ERN 001219322-33 (ភាសាអង់គ្លេស), កថាខណ្ឌទី ២១ ។

[18] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការឃុំខ្លួន កថាខណ្ឌទី៦៤-៦៦ ។ *សូមអានផងដែរ* នូវ ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY៖ *ក្នុងករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Popovic,* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍អំពីបញ្ហាបន្ទាន់បន្ទំរបស់មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធមិនព្រមដោះលែង Ljubomir Borovcanin ជាបណ្តោះអាសន្ន, សំណុំរឿងលេខ IT-05-88-AR65.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១ មីនា ២០០៧, កថាខណ្ឌទី១៣ ។ *ក្នុងករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Hradinaj* , សេចក្តីសម្រេចលើញត្តិស្នើសុំដោះលែងជាបណ្តោះអាសន្នរបស់ Lahi Brahimaj សំណុំរឿងលេខ IT-04-84-PT, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី៣ ឧសភា ២០០៦, កថាខណ្ឌទី១៦ ។

តែបំពេញបានគ្រប់គ្រាន់ជាងដែល ដែរឬទេ? ក្នុងករណីបើមានកំហុសឆ្គងនៅក្នុងដីកាសម្រេចណាមួយដែលកំពុងមានការតវ៉ា។ អ.ប.ជមានឆន្ទានុសិទ្ធិក្នុងការ“ទទួលភារៈធ្វើការវិភាគមួយរបស់ខ្លួនផ្ទាល់ ដោយប្រើប្រាស់នូវបទដ្ឋានដូចដែលមានចែងនៅក្នុងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុង”[19] និងធ្វើការកែប្រែនូវកំហុសឆ្គងនោះ ដោយដាក់បញ្ចូលសំអាងហេតុរបស់ខ្លួនផ្ទាល់នេះ ជំនួសវិញ[20] ។ គ្រប់ករណីទាំងអស់ដូចដែលមានចែងនៅក្នុងសេចក្តីសម្រេចជាបន្តបន្ទាប់របស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន អ.ប.ជ បានពិនិត្យពិចារណាលើសំណុំរឿងទាំងមូលរហូតទល់នឹងពេលធ្វើសវនាការ[21] ដែលក្នុងនោះរួមទាំងការពិនិត្យពិចារណាលើធាតុផ្សំថ្មីៗណាមួយ ឬភស្តុតាងណាមួយដែលបានដាក់ចាប់តាំងពីពេលមានប្តឹងឧទ្ធរណ៍មក។ ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមជូនជាយោបល់ថា នៅក្នុងបណ្តឹងឧទ្ធរណ៍ បច្ចុប្បន្ន អ.ប.ជ មិនគ្រាន់តែយកចិត្តទុកដាក់តែទៅលើភស្តុតាងថ្មីៗ ដែលបានដាក់មកចាប់តាំងពី ពេលចេញសាលដីកាសម្រេចរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវយកចិត្តទុក ដាក់ទៅលើការពិតដែលថា ជនត្រូវចោទ [redacted] ។

*ការអនុវត្តន៍ឆន្ទានុសិទ្ធិក្នុងការពិចារណាអំពីការឃុំខ្លួន*

៩. សមត្ថកិច្ចណាមួយរបស់តុលាការ អាចប្រើឆន្ទានុសិទ្ធិក្នុងការកំណត់អំពីថា តើការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដែរឬទេ? ឬមួយក៏ថា តើការឃុំខ្លួននេះ សមនឹងត្រូវបន្តថិរវេលាដែរឬទេ? ឆន្ទានុសិទ្ធិបែបនេះ ជាធម្មតាត្រូវបានអនុវត្តដោយត្រូវយកចិត្តទុកដាក់ទៅលើរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿង និងទៅលើអង្គហេតុដែលពាក់ព័ន្ធទាំងអស់នៃរឿងដែលរួមទាំងទម្ងន់នៃបទចោទ ភាពសមហេតុសមផលនៃភស្តុតាង អត្តចរិតកន្លងមក និងក្នុងពេលបច្ចុប្បន្ន និង

---

[19] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការឃុំខ្លួន, ឯកសារលេខ C 20/I26 , ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់លេខ 00201592, កថាខណ្ឌទី១៨ ។

[20] អ.ប.ជ បានចែងនៅក្នុងកថាខណ្ឌទី៤២ នៃសាលដីលាសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន (ឯកសារលេខ C 20/I/26 ) ថា “*អ.ប.ជ សង្កេតឃើញថែមទៀតថា សេចក្តីកង្វល់ណាមួយដែលលើកឡើងដោយសហមេធាវីការ ពារក្តីអំពីថា តើសហចៅក្រមស៊ើបអង្កេត មានមិនគោរពតាមគោលការណ៍សច្ចធារណ៍នីរទោសដែរ ឬទេនោះ គឺត្រូវបានដោះស្រាយរួចហើយដោយសេចក្តីវិភាគមួយដែលអង្គជំនុំជម្រះនេះបានទទួលធ្វើ*” ។

[21] ឧទាហរណ៍ដូចជា សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន, ឯកសារលេខ C 20/I/26, ERN 00201588-604 (ភាសាងង់គ្លេស), ត្រង់លេខ ០០២០១៥៩២, កថាខណ្ឌទី ២០ ។

អាកប្បកិរិយារបស់ជនត្រូវចោទ ផលប្រយោជន៍របស់សាក្សី ហើយនិងផលប្រយោជន៍ សម្រាប់យុត្តិធម៌ទាំងមូល[22] ។ ទម្លាប់អនុវត្តន៍ដែលត្រូវបានទទួលយល់ព្រមនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ក៏ត្រូវបានតុលាការនេះ អនុម័តយកតាមដែរ[23] ។

## ៣. អំណះអំណាង

### ក. បញ្ហាស្តីពីបន្ទុកនៃភស្តុតាង

១០. ចំពោះបញ្ហាស្តីពីបន្ទុកនៃភស្តុតាង មេធាវីការពារក្តីបានលើកសំអាងថា "វិធាន៦៣.៧ បានដាក់បន្ទុកទៅលើសហចៅក្រមស៊ើបអង្កេត"[24] ។ ការលើកសំអាងនេះ គឺជាការខុស ។ សហចៅក្រមស៊ើបអង្កេត គ្រាន់តែមានកាតព្វកិច្ច ក្នុងការធ្វើការប៉ាន់ប្រមាណ វាយតម្លៃឡើងវិញ អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ឱ្យការបន្តការឃុំខ្លួនតទៅទៀត ត្រូវបានបំពេញគ្រប់គ្រាន់ហើយតែប៉ុណ្ណោះ ដោយគិតគូរយកចិត្តទុកដាក់ទៅលើរាល់ភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង និងទៅលើសេចក្តីសង្កេតណាមួយរបស់មេធាវីការពារក្តី។ នៅក្នុងវិធានមិនបានដាក់បន្ទុកបែបនេះណាមួយដើម្បីឱ្យ ស.ច.ស ត្រូវតែបំពេញឱ្យបានគ្រប់គ្រាន់នោះទេ ។ ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនលើកទី២ មានផ្តល់សំអាងហេតុ និងបានពិនិត្យពិចារណាទៅលើគ្រប់លក្ខខណ្ឌទាំងអស់យ៉ាងត្រឹមត្រូវ។

### ខ. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ មានអត្ថិភាពដែលធ្វើឱ្យជឿថា ដើមបណ្តឹងឧទ្ធរណ៍ទំនងជា បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នោះមែន-វិធាន ៦៣.៣.ក

១១. តួនាទីរបស់ ស.ច.ស នៅក្នុងវិធាន៦៣.៣.ក នៃវិធានផ្ទៃក្នុងនោះ គឺត្រូវធ្វើការថ្លឹងថ្លែងភស្តុតាងទាំងអស់ជារួម ដែលប្រមូលបានគិតមកទល់នឹងពេលបច្ចុប្បន្ននេះតាមដីកាបង្គាប់របស់ខ្លួន និងធ្វើការកំណត់ថា តើមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទទំនងជាបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មនានា ដូចដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

[22] *ក្នុងករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski*, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ហាបន្ទាន់បង្ខំរបស់ *Johan Tarculovski* ស្តីពីការដោះលែងជាបណ្តោះអាសន្ន, សំណុំរឿង លេខ IT-04-82-AR65.4, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧ កក្កដា ២០០៧, កថាខណ្ឌទី៤ ។

[23] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ស្តីពីការដោះលែងជាបណ្តោះអាសន្ន, កថាខណ្ឌទី២៧។

[24] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៧។

00426525



និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះមែនដែរ ឬទេ? ។ មេធាវីការពារក្ដីហាក់ដូចជាបានធ្វើការបកស្រាយខុសអំពីការសាកល្បងនេះដោយលើកឡើងថា ស.ច.ស បានកំណត់អំពីអត្តសញ្ញាណដោយខ្លួនឯងផ្ទាល់នូវភស្តុតាងដោះបន្ទុកមួយចំនួន ក្នុងចំណោមភស្តុតាងដោះបន្ទុកដ៏មានសក្ដានុពលទាក់ទងទៅនឹងជនត្រូវចោទ[25], មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាគាត់ទំនង ជាបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មនានាដែលរូបគាត់កំពុងតែត្រូវបានធ្វើការស៊ើបនោះ គឺមិនមានអត្ថិភាពទេ ។

១២. នេះគឺជាការលើកសំអាងដែលធ្វើឲ្យខ្លួនឯងបរាជ័យ ដោយសារតែការលើកឡើងនោះ បានគូសបញ្ជាក់ពីការពិតថា តាមពិតទៅគឺ ស.ច.ស បានយកចិត្តទុកដាក់ទៅលើភស្តុតាងដោះបន្ទុក ដែលមាននៅក្នុងសំណុំរឿង និង"ទោះជាយ៉ាងណាក៏ដោយ...ក៏[មិន]បានចាត់ទុកថា ភស្តុតាងនេះគ្រប់គ្រាន់សម្រាប់ធ្វើឲ្យក្លាយជាមោឃៈនូវមូលដ្ឋានសម្រាប់មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់"ថា លក្ខខណ្ឌដូចដែលមានចែងនៅក្នុងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុងត្រូវបានបំពេញគ្រប់គ្រាន់ហើយនោះដែរ[26] ។

១៣. លើសពីនេះ ការអនុវត្តតាមសេចក្ដីណែនាំក្នុងសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អ.ប.ជ ដែលណែនាំ "ថា ខ្លួនមានបំណងចង់ឲ្យ [ស.ច.ស] ផ្ដល់សេចក្ដីឲ្យបានលំអិតជាងនេះ ទាក់ទងអំពីភស្តុតាងដែល ស.ច.ស ប្រមូលបានដែលគាំទ្រចំពោះសេចក្ដីសន្និដ្ឋានរបស់ខ្លួន"[27] ស.ច.ស បានលើកឡើងយ៉ាងច្បាស់ដោយយោងទៅលើដីកាសម្រេចរបស់ខ្លួនដែលក្នុងនោះ ខ្លួនបានពឹងផ្អែកទៅចម្លើយរបស់សាក្សីថ្មីចំនួនជាងសាមសិបនាក់ ដើម្បីឈានទៅធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន[28]។ ហេតុដូចនេះ គឺសេចក្ដីសម្រេចរបស់ ស.ច.ស បានផ្ដល់នូវសំអាងហេតុ និងសេចក្ដីលំអិត រួចហើយ ។ នៅក្នុងសំណុំរឿងមានភស្តុតាងដែលអាចបំពេញបានតាមសេចក្ដីត្រូវការ របស់អ្នក

---

[25] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី ១១។

[26] ដីកាសម្រេចបន្តឃុំខ្លួនលើកទី២ កថាខណ្ឌទី.២០ ។

[27] សាលដីកាសម្រេចរបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍,កថាខណ្ឌទី ១៣៧។

[28] ដីកាសម្រេចបន្តឃុំខ្លួនលើកទី២, កថាខណ្ឌទី ១៨.ក ដល់ ១៨.ង ។ ចម្លើយថ្មីៗទាំងនេះ ជួយពង្រឹងដល់ភស្តុតាងដាក់បន្ទុកដ៏ច្រើនអនេកដែល ស.ច.ស ប្រមូលបានចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០៧មក។ សហព្រះរាជអាជ្ញា បានដាក់បញ្ចូលនូវចម្លើយនេះដោយយោងទៅលើដីកាសន្និដ្ឋាន របស់ខ្លួនដូចដែលមានចែងនៅក្នុងកថាខណ្ឌទី២៩ ដល់ទី៣៧ នៃ " ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ វិច្ឆិកា ២០០៨ ", ដែលបានដាក់កាលពីថ្ងៃទី ៩ មករា ២០០៩។

00426526



សង្កេតការណ៍ឯករាជ្យនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរដែលថា ដើមបណ្តឹងឧទ្ធរណ៍ទំនងជាបានប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលរូបគាត់កំពុងតែត្រូវបានធ្វើការស៊ើបសួរ ។

**ឃ. ការឃុំខ្លួនបណ្តោះអាសន្ន ស្ថិតនៅជាវិធានការដ៏ចាំបាច់ ដើម្បីធានាឲ្យប្រាកដប្រជា ចំពោះសន្តិសុខរបស់ដើមបណ្តឹងឧទ្ធរណ៍ជាងដែល**

១៤. អ.ប.ជ បានសម្រេច កាលពីថ្ងៃទី៣ ខែកក្កដាឆ្នាំ២០០៩ ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ផ្អែកតាមវិធាន៦៣.៣.ខ.៤ នៃវិធានផ្ទៃក្នុង ហើយការដោះលែងដើមបណ្តឹងឧទ្ធរណ៍អាចនឹងបណ្តាលឲ្យមានជាអំពើហិង្សាប្រឆាំងនឹងរូបគាត់ដោយផ្អែកលើមូលដ្ឋាននៃប្រតិកម្មផ្សេងៗដែលជនរងគ្រោះនានាបានបង្ហាញចេញមក និងដូចដែលអ្នកជំនាញផ្នែកចិត្តសាស្ត្រនានា បានរំពឹងទុក[29]។ សនិទានភាពដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ អ.ប.ជ គឺស្ថិតនៅជាធរមានដដែល លើអង្គហេតុ និងភស្តុតាងទាំងឡាយដែលកំពុងតែមានស្រាប់នៅក្នុងពេលបច្ចុប្បន្ននេះ ហើយដែលដើមបណ្តឹងឧទ្ធរណ៍គ្មានផ្តល់នូវភស្តុតាងអ្វីដើម្បីបង្ហាញឲ្យឃើញថា ការរកឃើញរបស់ ស.ច.ស លើបញ្ហានេះ គឺជាការមិនត្រឹមត្រូវនោះសោះឡើយ ។

១៥. មេធាវីការពារក្តីបានលើកឡើងថា មិនមានហានិភ័យជាក់ស្តែង និងដែលមានវត្តមាន សម្រាប់ដើមបណ្តឹងឧទ្ធរណ៍នោះទេ "ព្រោះដោយសាររូបគាត់ខ្លួនឯងផ្ទាល់មិនមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់គាត់ផង")[30]។ សូមជូនជាយោបល់ថា ទី១ គឺមិនមែនដើមបណ្តឹងឧទ្ធរណ៍ជាអ្នកដែល ត្រូវធ្វើការកំណត់នោះទេ។ ទី២ អារម្មណ៍របស់ជនរងគ្រោះមួយចំនួន ត្រូវបានសំដែងចេញមកនៅ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើករណីរឿង ឌុច នៅពេលថ្មីៗនេះ បានបញ្ជាក់ពីការរកឃើញជាច្រើនថា មានជនរងគ្រោះក្នុងចំនួនដ៏ច្រើន មានអារម្មណ៍ហឹង្សាចំពោះដើមបណ្តឹងឧទ្ធរណ៍ និងថា អារម្មណ៍ទាំងនេះ អាចងាយនឹងប្រែក្លាយទៅជាប្រតិកម្មដោយ អំពើហឹង្សាទៅលើរូបគាត់បាន បើសិនជារូបគាត់ត្រូវបានដោះលែង ។ ជាពិសេស ចម្លើយដែលត្រូវបានផលិតឡើងវិញជាថ្មីដូចខាងក្រោមនេះ បង្ហាញដោយមិនបាច់មានការសង្ស័យទេថាហានិភ័យ គឺមានវត្តមាន ហើយជាក់ស្តែងទៀត៖

---

[29] សាលដីកាសម្រេចរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៥៧ ។

[30] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១៧ ។

*" ឌុច ខ្ញុំទទួលស្គាល់លោកចំពោះការឆ្លើយទទួលទោស។ ខ្ញុំមានការខឹងសម្បារលើពាក្យសំដីជាមួយលោក និងចំពោះអ្វីដែលលោកបានធ្វើ, ក៏ប៉ុន្តែខ្ញុំទទួលស្គាល់ និងគោរពចំពោះការឆ្លើយទទួលទោសរបស់លោក ។ ការទទួលស្គាល់របស់លោក គឺតូចមួយប៉ុណ្ណោះ ប៉ុន្តែជាការចូលរួមចំណែកដ៏សំខាន់ក្នុងការដោះស្រាយការខូចខាតដែលលោកបានបង្កឡើង។* ***ជនទាំងឡាយដែលមិនបានឆ្លើយទទួលទោស និងមិនទទួលយល់ព្រមចំពោះការខូចខាតដែលពួកគេបានបង្កឡើង គឺវាស្មើនឹងការស្លាប់ខ្លួនទាំងអស់ និងគួរឱ្យអស់សំណើចរបស់ពួកគេ ទ្វេរជាពីរដង***[31] ។

*" ឌុច ពេលខ្លះ ខ្ញុំចង់តែកំទេចលោក -- ដោយប្រើពាក្យរបស់លោក -- ក្នុងរបៀបដូចដែលលោកបានកំទេចអ្នកដទៃទៀតជាច្រើន។ ពេលខ្លះ ខ្ញុំបានស្រម៉ៃឃើញថា លោកត្រូវជាប់ខ្នោះជើង អត់អាហារ ត្រូវគេវាត់នឹងខ្សែតី និងត្រូវគេវាយនឹងដំបងយ៉ាងសាហាវឃោរឃៅ។ ខ្ញុំបានស្រម៉ៃឃើញថា ម្ចោកពងរបស់លោកត្រូវបានគេឆក់នឹងខ្សែភ្លើង កំពុងត្រូវបានគេបង្ខំឱ្យស៊ីអាចម៍របស់ខ្លួនឯង កំពុងតែហៀបនឹងលង់ទឹក និង កំពុងឃើញបំពង់ខ្យល់របស់លោកត្រូវបានគេកាត់ផ្តាច់ ។ ខ្ញុំមានបំណងចង់ឱ្យលោកទទួលនូវបទពិសោធន៍ទាំងនោះវិញ អំពីភាពជាក់ស្តែងរបស់លោក" ។ ខ្ញុំមានបំណងចង់ឱ្យលោកទទួលរងនូវការឈឺចាប់ដូចដែលលោក បានធ្វើទៅលើ Kerry និងទៅលើអ្នកដទៃជាច្រើនទៀត"*[32] ។

*" អញ្ចឹងខ្ញុំសូមនិយាយប្រាប់រឿងនេះទៅឌុច ថា* ***ឌុច គាត់មិនបានវាយខ្ញុំដោយខ្លួនឯងដោយផ្ទាល់នោះទេ បើពុំនោះទេ គាត់មុខជានឹងមិនមានថ្ងៃបានឃើញពន្លឺព្រះអាទិត្យឡើយ ។ ខ្ញុំគ្រាន់ តែសូមនិយាយដោយត្រង់"***[33] ។

១៦. ពិតមែនហើយថា ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាជាជនគ្មានទោស ដរាបណានៅតែគ្មានភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពរបស់គេ ហើយត្រូវមានសិទ្ធិទទួលបាននូវការការពារដ៏មាំមួនៅក្នុងដំណើរការនីតិវិធីទៀតផង។ យ៉ាងណាក៏ដោយ អារម្មណ៍ខាងលើទាំងនេះ ឆ្លុះបញ្ចាំងនូវសញ្ញា

[31] ប្រតិចារិក នៃដំណើរការនីតិវិធីជំនុំជម្រះករណី កាំហ្កេក អ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី១៧ សីហា ២០០៩, ឯកសារលេខ E1/63.1 ទំព័រ ៩៣, ERN 00365783-5905 (ភាសាអង់គ្លេស) ។

[32] ប្រតិចារិក នៃដំណើរការនីតិវិធីជំនុំជម្រះករណី កាំហ្កេក អ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី១៧ សីហា ២០០៩, ឯកសារលេខ E1/63.1 ទំព័រ ១០៤ និង១០៥ , ERN 00365783-5905 (ភាសាអង់គ្លេស) ។

[33] ប្រតិចារិក នៃដំណើរការនីតិវិធីជំនុំជម្រះករណី កាំហ្កេក អ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី៣០ មិថុនា ២០០៩, ឯកសារលេខ E1/40.1 ទំព័រ១២, ERN 00346456-6552 (ភាសាអង់គ្លេស) ។

យល់ដឹងដ៏ខ្លាំងក្លា (strong perception) របស់ជនរងគ្រោះមួយចំនួនធំនៃរបបកម្ពុជា ប្រជាធិបតេយ្យ ដែលថាជនដែលមិនបាន "សារភាពថាមានពិរុទ្ធភាព" គឺ "doubly worthy of all their hate - សមតែនឹងត្រូវបានស្អប់ពីរដង/យ៉ាង" ។ ជាការបន្ថែមទៅនឹងឧប្បត្តិហេតុ ពីលើកមុន ដែលបានសំដៅជាពិសេសទៅរកដើមបណ្តឹងឧទ្ធរណ៍ និង/ឬ ក្រុមមេធាវីរបស់គាត់ អារម្មណ៍នេះគាំទ្រដល់ការរកឃើញដែលថា បើដើមបណ្តឹងឧទ្ធរណ៍ត្រូវបានដោះលែងនោះ សន្តិសុខរបស់គាត់មុខជានឹងត្រូវធ្វើឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរជាមិនខាន។ ដោយសារមានជនរងគ្រោះសក្តានុពលចំនួនដ៏ច្រើន និងវិសាលភាពយ៉ាងធំសម្បើមនៃបុគ្គលដែលអំពើហិង្សាអាចនឹងចាប់ផ្តើមបញ្ចេញពីពួកគាត់សំដៅចំពោះដើមបណ្តឹងឧទ្ធរណ៍នោះនឹងពុំមាន វិធានការដទៃណាទៀតទេ ក្រៅតែពីការបន្តឃុំខ្លួនគាត់នោះ ទើបអាចធានាបានយ៉ាងពេញលេញ ដើម្បីទប់ទល់នឹងហានិភ័យបែបនេះ។

១៧. លើសពីនេះ ពាក់ព័ន្ធនឹងហានិភ័យដែលបណ្តាលមកពីជនរងគ្រោះ ចំពោះសន្តិសុខរបស់ជនត្រូវចោទនានា និងការយោង ក៏ត្រូវបានធ្វើឡើងផងដែរទៅដល់ឧប្បត្តិហេតុនានា និងពាក្យដែលប្រកបទៅដោយទោសៈ ដែលមានសេចក្តីពិស្តារនៅក្នុងកថាខ័ណ្ឌទី ៤០ នៃ "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨" ដែលបានដាក់ជូននៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៩ ។

## ង. ការឃុំខ្លួនបណ្តោះអាសន្ន នៅតែជាវិធានការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ

១៨. អបជ បានកំណត់កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨ ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាការចាំបាច់ទៅតាមវិធាន ៦៣.៣.ខ(៥) នៃវិធានផ្ទៃក្នុង ដោយហេតុថា ការដោះលែងដើមបណ្តឹងឧទ្ធរណ៍ នឹងពិតជាអាចបណ្តាលឱ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈ[34] ។ សចស មិនបានរកឃើញ ថាមានការផ្លាស់ប្តូរណាមួយនៅក្នុងកាលៈទេសៈសំខាន់ៗនៅឡើយទេ ព្រោះថាសេចក្តីសម្រេចរបស់ អបជ បានធ្វើឱ្យពួកគេឈានទៅដល់សេចក្តីសម្រេចផ្សេងមួយទៀត[35] ។ នៅក្នុងបញ្ហានេះ ដើមបណ្តឹងឧទ្ធរណ៍បានជំទាស់ថា ភាពផុយស្រួយនៃសង្គមកម្ពុជា គឺឋិតនៅឆ្ងាយពីការគិតដូច្នេះ ហើយវាមិនអាចនិយាយបានទេថា ការដោះលែងរូបគាត់ មុខជាអាចធ្វើឱ្យខូចដល់

[34] សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៦២ ។

[35] ដីកាសម្រេចបន្តឃុំខ្លួនលើកទី ២, កថាខ័ណ្ឌទី ២៧ ។

សណ្តាប់ធ្នាប់សាធារណៈជាមិនខាន[36]។ យ៉ាងនេះក៏ដោយ ក៏ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ភស្តុតាងអ្វីថ្មីណាមួយនៅឡើយដែលអាចនឹងធ្វើឱ្យ អបជ សម្រេចផ្សេងពីការយល់ឃើញរបស់ខ្លួនបានទេ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញា សន្និដ្ឋានថា សនិទានភាពដែលបានលើកឡើងនៅក្នុងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនលើកទីពីរ និងសាលដីការបស់ អបជ សម្រេចលើបណ្តឹងឧទ្ធរណ៍ គឺកំពុងនៅមានសុពលភាពនៅឡើយ ។

១៩. បន្ថែមលើនេះ សហព្រះរាជអាជ្ញា យោងទៅដល់សក្ខីកម្មរបស់អ្នកជំនាញ បណ្ឌិត ឈឹម សុធារ៉ា ក្នុងអំឡុងពេលសវនាការរបស់ ឌុច កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ។ អ្នកជំនាញរូបនេះបានពិភាក្សាអំពី ជម្ងឺតានតឹងខាងផ្លូវចិត្តក្រោយពីមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរ (post-traumatic stress disorder - "PTSD") និងអំពីឥទ្ធិពលប៉ះពាល់ខាងផ្លូវចិត្តយ៉ាងទូលំទូលាយ ទៅលើជនរងគ្រោះដែលទទួលរងនូវការប៉ះទង្គិចនានា[37]។ គាត់មានទស្សនៈថា ជនរងគ្រោះជាច្រើនដែលបានទទួលរងនូវការប៉ះទង្គិច គឺថិតនៅក្រោមការធ្លាក់ចុះនៃកម្លាំងចិត្ត ការខឹងសម្បារ រោគញៀនស្រា និងអំពើហិង្សាក្នុងគ្រួសារ[38] ។ គាត់បានសង្កត់បន្ថែមថា ការធ្វើឱ្យជនរងគ្រោះ សះជាតាមផ្លូវចិត្តឡើងវិញ គឺអាស្រ័យនៅលើភាពស្មោះត្រង់ដែលពួកអតីតមេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យបង្ហាញ ឬសម្តែងចេញ ឬទទួលស្គាល់ថាអវត្តមាន/ការប្រកែកមិនទទួលខុសត្រូវ គឺជាបន្ទុកមួយបន្ថែមទៀត ដាក់ទៅលើជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូល ហើយថាពួកជនរងគ្រោះមិនសប្បាយចិត្តទេ និងមានអារម្មណ៍ខឹងសម្បារយ៉ាងខ្លាំងបណ្តាលមកពីការប្រកែកបែបនេះ[39] ។ អ្នកជំនាញរូបនេះបានថ្លែងថា ដំណើរការនីតិវិធីជំនុំជម្រះក្តីនៅចំពោះមុខ អវតក បាននាំឱ្យមានការប៉ះទង្គិចសារជាថ្មីទៅលើជនរងគ្រោះមួយចំនួន[40] ។ លើសពីនេះទៅទៀត "ប្រមាណជា

---

[36] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២៣ ។

[37] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី២៥ សីហា ២០០៩, E1/68.1, ERN 00370950-1055 (ភាសាអង់គ្លេស) ។

[38] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី២៥ សីហា ២០០៩, E1/68.1, ត្រង់ទំព័រទី ១៥-១៦/៤២, ERN 00370967-68/94 (ភាសាអង់គ្លេស) ។

[39] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី២៥ សីហា ២០០៩, E1/68.1, ត្រង់ទំព័រទី ៣៨, ERN 00370990 (ភាសាអង់គ្លេស) ។

[40] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី២៥ សីហា ២០០៩, E1/68.1, ត្រង់ទំព័រទី ១៨ និង ៥៩, ERN 00370970 និង 00371011 (ភាសាអង់គ្លេស) ។ សូមមើលផងដែរ *Pour une meilleure justice, il faut aussi un soutien psychologique aux victims*, Cambodge soir, Chheang Bopha, 29 septembre 2006, accessible at http://www.cambodgesoir.info/index.php?option=com_content&view=article&catid=43%3Aarchives&id=20365%3Apour-une-meilleure-justice-il-faut-aussi-un-soutien-psychologique-aux-victimes&Itemid=46 ; Now

00426530



៣០% នៃប្រជាជនកម្ពុជាចំនួន ១៤ លាននាក់ ត្រូវបានរាយការណ៍មកថាបានទទួលរងនូវការឈឺចាប់បណ្ដាមកពី a debilitating mental condition - from anxiety and chronic unexplained physical pain to unpredictable mood swings or sudden eruptions of rages"[41] ហើយជនរងគ្រោះមួយចំនួនធំ ចម្លងការប៉ះទង្គិចរបស់ខ្លួន ពីជំនាន់មួយទៅជំនាន់មួយទៀត[42] ។ នៅក្នុងដំណាក់ការនៃដំណើរការនីតិវិធី ដែលការស៊ើបសួរ ជិតចូលដល់ទីបញ្ចប់ការដោះលែងដើមបណ្ដឹងឧទ្ធរណ៍ ច្បាស់ជានឹងបណ្ដាលឱ្យស្ថានភាពផ្សេងៗរបស់ជនរងគ្រោះកាន់តែមានភាពធ្ងន់ធ្ងរឡើងជាមិនខាន ហើយជាលទ្ធផល នឹងបណ្ដាលឱ្យមានហានិភ័យយ៉ាងធំចំពោះសណ្ដាប់ធ្នាប់សាធារណៈ ។

## ច. ការកន្លងផុតទៅនៃពេលវេលា ភាពលំអៀង និង អំពើពុករលួយ

២០. មេធាវីការពារក្ដីបានសម្អាងថា សចស មិនបានបំពេញកិច្ចស៊ើបសួររបស់ខ្លួនដែលប្រកបទៅដោយការព្យាយាមដ៏សមហេតុផលទេ[43]។ ពេលវេលានៃការឃុំខ្លួន ត្រូវបានពិចារណាដោយ តុលាការអន្តរជាតិនានា ថាជាកត្តាពាក់ព័ន្ធមួយនៅក្នុងការកំណត់អំពីភាពត្រឹមត្រូវតាមច្បាប់នៃ ការឃុំខ្លួន[44] សហព្រះរាជអាជ្ញាយល់ឃើញថា សចស បានធ្វើឱ្យមានការជឿនលឿនយ៉ាងច្រើន នៅក្នុងការ

Prozac Battles Dark Dreams That Khmer Rouge Left, The New York Times, Phnom Penh Journal, 16 February 2006,accessible at http://www.nytimes.com/2006/02/16/international/asia/ 16cambodia.html?_r =1&pagewanted =print , where Chhim Sotheara "said his concerns were "retraumatization" of survivors who will come face to face with the past; new trauma on young people who did not experience the Khmer Rouge era; and renewed anger and hostility among victims"

[41] *Cambodia's long look backwards; doctors struggle to heal troubled country*, AFP, 3 September 2007, http://afp.google.com/article/ALeqM5idAIOjK3ixMBq5JqFvuqDOZaRtcg?index=0

[42] *Des psychiatres au secours des victims enfermées dans leurs cauchemars*, Cambodge Soir, 11 mars 2005, accessible at http://www.cambodgesoir.info/index.php?view=article&catid=43:archives&id=16087:des-psychiatres-au-secours-des-vicitmes-enfermees-dans-leurs-cauchemars&format=pdf&option=com_content

[43] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២៧ ។

[44] *ករណីរដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic*, ដីកាសម្រេចបដិសេធលើញត្តិស្នើសុំឱ្យមានការដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-94-14- អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦៖ តុលាការ ICTY បានលើកឡើងនៅក្នុងសេចក្ដីសម្រេចនោះថា ដើម្បីបង្កើតឱ្យមានជាលក្ខណៈសមហេតុផលមួយនៃរយៈពេលឃុំខ្លួនបណ្ដោះអាសន្ន នោះវាចាំបាច់ត្រូវធ្វើការវាយតម្លៃទៅលើកាលៈទេសៈនៃករណីនីមួយៗ ដោយមានមូលដ្ឋាននៅលើលក្ខណៈវិនិច្ឆ័យដូចតទៅ៖ ក) រយៈពេលដ៏មានប្រសិទ្ធិភាពនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ។ ខ) រយៈពេលឃុំខ្លួន បណ្ដោះអាសន្នដែលមានការទាក់ទងទៅនឹងប្រភេទនៃឧក្រិដ្ឋកម្ម ។ គ) ផលវិបាកខាងផ្លូវរាងកាយ និងផ្លូវចិត្តនៃការឃុំខ្លួនទៅលើជនជាប់ ឃុំឃាំង ។ ឃ) ភាពស្មុគស្មាញនៃសំណុំរឿង និងការស៊ើបអង្កេតនានា ។ ង) ដំណើរប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីទាំងមូល ។ ស្ថានភាព នៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui, ការពិនិត្យឡើងវិញអំពីសាលដីកាលើពាក្យសុំឱ្យមានការដោះលែង Mathieu Ngudjolo Chui ជាបណ្ដោះអាសន្ន, សំណុំរឿងលេខ 01/04-01/07, អង្គបុរេជំនុំជម្រះនៃតុលាការ ICC, ចុះថ្ងៃទី២៣ កក្កដា ២០០៨, ទំព័រទី ១២ ។

ស៊ើបសួររបស់ខ្លួន ដែលមានការជូនដំណឹងក្នុងពេលថ្មីៗដល់ដើមបណ្ដឹងឧទ្ធរណ៍ជាភស្តុតាងស្រាប់ ដែលថា[redacted]

២១. ដោយសារមានភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ភាពស្មុគស្មាញនៃសំណុំរឿងនេះ និងវិសាលភាពនៃការស៊ើបសួរដែលកំពុងបន្ត នោះរយៈពេលនៃការឃុំខ្លួនដើមបណ្ដឹងឧទ្ធរណ៍ជាបណ្ដោះអាសន្ន គឺមានលក្ខណៈសមហេតុផល ។ កិច្ចធានាទាំងឡាយដែលមាននៅក្នុងវិធានផ្ទៃក្នុង បានកំរិតរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន និងបានផ្ដល់នូវប្រព័ន្ធមួយសម្រាប់ជាច្រកក្នុងការពិនិត្យសារឡើងវិញជាប្រចាំនូវកង្វល់នានា ដែលថារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន អាចនឹងមានការបំពានទៅលើសិទ្ធិរបស់ដើមបណ្ដឹងឧទ្ធរណ៍ ។

២២. មេធាវីការពារក្ដីក៏បានសម្អាងផងដែរថា អំពើពុករលួយផ្សេងៗ បានគ្របដណ្ដប់លើនីតិវិធី ហើយការស៊ើបអង្កេតទៀតសោត ក៏មិនបានអនុវត្តក្នុងក្របខណ្ឌនៃតម្លាភាពដែរ[45] ។ បណ្ដឹងឧទ្ធរណ៍នេះមិនមែនជាវេទិកាដ៏ត្រឹមត្រូវមួយសម្រាប់លើកឡើងនូវបញ្ហានានាបែបដូច្នោះនោះទេ ដែលថាបញ្ហាទាំងនេះ តាមពិតទៅត្រូវបាន អបជ ធ្វើការដោះស្រាយរួចហើយៗក៏ត្រូវបានច្រានចោលរួចហើយដែរ ។ ហេតុដូច្នេះ សេចក្ដីសម្អាងនេះត្រូវបានរាំងដោយ *អាជ្ញាអស់ជំនុំ (res judicata)* ។

២៣. *អាជ្ញាអស់ជំនុំ (res judicata)* ក៏អនុវត្តផងដែរចំពោះសេចក្ដីសម្អាងដែលសហមេធាវីអន្តរជាតិនៃក្រុមការពារក្ដី ពុំមានលទ្ធភាពប្រកបដោយប្រសិទ្ធិភាព ក្នុងការពិនិត្យនូវភស្តុតាង ដែលមានផ្ទុកនៅក្នុងសំណុំរឿង[46]។ សេចក្ដីសម្អាងនេះដែលត្រូវបានលើកឡើង ជាច្រើនលើកច្រើនសាររួចមកហើយៗក៏ត្រូវបានច្រានចោល ផងដែរ[47] បាននាំឲ្យមានការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃ របស់អង្គជំនុំជម្រះ ហើយគួរតែត្រូវបាន បដិសេធចោលដោយពុំចាំបាច់ធ្វើការពិចារណាអ្វីបន្ថែមទៀតទេ

## ឆ. ជម្រើសផ្សេងទៀតក្នុងការឃុំខ្លួន មិនសមស្របតាមភាពចាំបាច់ សម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន

[45] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី ៣៣ ។

[46] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី ៣៣ ។

[47] *ករណីរបស់ ខៀវ សំផន,* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី២០ កុម្ភៈ ២០០៩, A190/I/20, ERN 00283249-62 ។

00426532



២៤. អបជ បានកំណត់កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ថា ការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អវតក គឺជាការចាំបាច់ទៅតាមវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង ហើយជម្រើសដទៃទៀតក្នុងការឃុំខ្លួនមិនសមស្របទៅតាមភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នទេ[46] ។ ដូចបានផ្តល់សក្ខីកម្មនៅខាងលើស្រាប់ ដោយហេតុថាភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ននៅមិនទាន់បានកាត់បន្ថយនៅឡើយ ដូច្នេះជម្រើសដទៃទៀតក្នុងការឃុំខ្លួន គឺនៅតែមិនសមស្របជាបន្តទៀត។ ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ភស្តុតាងអ្វីដែលអាចនឹងធ្វើឲ្យ អបជ យល់បានផ្សេងពីនេះនៅឡើយទេ ។ លើសពីនេះទៀត ដោយហេតុថា ពុំមានអត្ថិភាពនៃការផ្លាស់ប្តូរកាលៈទេសៈណាមួយ ដែលអាចនឹងធ្វើឲ្យមានការយល់ព្រមទទួលយកជម្រើសផ្សេងៗទៀតថាជាការពិតបាន សចស មិនបានរំលោភ ទៅលើឆន្ទានុសិទ្ធិរបស់ខ្លួនទេ ឬក៏ខកខាន ពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួន ទៅតាមវិធាន ២១.១ និង ២១.២ នៃវិធានផ្ទៃក្នុងនោះក៏ទេដែរ ។

២៥. ហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យ អបជ សម្រេចថាលក្ខខណ្ឌនានានៃការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អវតក គឺកំពុងនឹងបន្តត្រូវទៅតាមវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង ដូច្នេះវាបានធ្វើយុត្តិកម្មទៅលើការបន្តថិរវេលានៃការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ ដោយច្រានចោលនូវជម្រើសដទៃទៀតទាំងអស់បាន ។

## ៤. សេចក្តីសន្និដ្ឋាន

២៦. សហព្រះរាជអាជ្ញា សូមស្នើឲ្យ អបជ បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | [signature] |
| | **លោក William SMITH**<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | [signature] |

[46] សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួន, កថាខណ្ឌទី ៩២ ។